អង្គការសមាគមធាងត្នោត

Sahmakum Teang Tnaut Organization • a Cambodian Urban NGO

លេខ: ០៩៨/២៤

# សេចក្តីប្រកាសដេញថ្លៃ លើការផ្គត់ផ្គង់សម្ភារៈផ្ទះឈើ

អង្គការសមាគមធាងត្នោត គឺជាអង្គការឯករាជ្យ មិនស្វែងរកប្រាក់ចំណេញ បានបង្កើតឡើងតាំងពីឆ្នាំ២០០៥ និងបានចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦។ **អង្គការសមាគមធាងត្នោត** មានគម្រោងចែកជូនសម្ភារៈផ្ទះឈើ ជូនដល់សហគមន៍គោលដៅ នៅក្នុងរាជធានីភ្នំពេញ ហើយនិងកំពុងស្វែងរក ក្រុមហ៊ុន ឬសហគ្រាស ដើម្បីចូលរួមដេញថ្លៃលើគម្រោងនេះ។ សម្រាប់ព័ត៌មានពាក់ព័ន្ធនឹងការដាក់ដេញថ្លៃ សូមទាញយក **បញ្ជីរាយនាមសម្ភារៈសម្រាប់ផ្តល់សម្រង់តម្លៃ** ។

**លក្ខខណ្ឌដែលក្រុមហ៊ុនត្រូវមាន៖**

- មានបទពិសោធន៍ក្នុងការដេញគម្រោងផ្គត់ផ្គង់សម្ភារៈផ្ទះឈើ យ៉ាងតិច ០២ឆ្នាំ ដោយភ្ជាប់ជាមួយនូវប្រវត្តិសង្ខេបរបស់ក្រុមហ៊ុន។
- លិខិតប្រកបអាជីវកម្ម ឬ វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម ឬ ប័ណ្ណប៉ាតង់ ដែលមានសុពលភាព
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (ក្នុងករណីដែលពុំបានចុះបញ្ជីពន្ធដារ ត្រូវផ្តល់សម្រង់តម្លៃដោយ មិនគិតបញ្ចូលពន្ធ)
- លិខិតបញ្ជាក់ទីតាំងក្រុមហ៊ុន ឬសហគ្រាស និង អត្តសញ្ញាណប័ណ្ណម្ចាស់ក្រុមហ៊ុន ឬសហគ្រាស
- ផ្តល់លិខិតសម្រង់តម្លៃលើគម្រោង (សូមទាញយក បញ្ជីរាយនាមសម្ភារៈសម្រាប់ផ្តល់សម្រង់តម្លៃដើម្បីបំពេញ)

**បែបបទនៃការដាក់ពាក្យ៖**

ប្រសិនបើលោក-លោកស្រីដែលជាម្ចាស់ក្រុមហ៊ុននានា មានចំណាប់អារម្មណ៍ក្នុងការដេញថ្លៃ សូមផ្តល់នូវលិខិតសម្រង់តម្លៃ ដោយភ្ជាប់ជាមួយនឹងឯកសារច្បាប់នានាដែលបានតម្រូវក្នុងលក្ខខណ្ឌខាងលើ **ដាក់ក្នុងស្រោមសំបុត្របិទជិត** រួចផ្ញើមកកាន់អង្គការសមាគមធាងត្នោត ដែលមានអាស័យដ្ឋាន ផ្ទះលេខ ២១ ផ្លូវលេខ ៤៧២ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់លេខទូរស័ព្ទ៖ **០២៣ ៤៣១៥ ៥៥៥ / ០៧៧ ៩៦៧ ២៨៦។**

**<u>កាលបរិច្ឆេទឈប់ទទួលពាក្យ៖</u>**

ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៤ វេលាម៉ោង ១២ថ្ងៃត្រង់ ។

**ជ. ប្រធានផ្នែករដ្ឋបាល និងធនធានមនុស្ស**

**ឈ្មោះ អ៊ុន កក្កដា**

**កាលបរិច្ឆេទ ៖ ២២ កក្កដា ២០២៤**

អាសយដ្ឋាន៖ ផ្ទះលេខ ២១ ផ្លូវលេខ៤៧២ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរសព្ទលេខ (៨៥៥)២៣ ៤៣១ ៥៥៥
ប្រអប់សំបុត្រលេខ ១៧៤ ភ្នំពេញ កម្ពុជា អ៊ីមែល info@teangtnaut.org គេហទំព័រ: www.teangtnaut.org
Address: #21, St 472, Tuol Toumpong I, Chamkar Mon, Phnom Penh. Tel: (855)23 431 555
P.O. Box 174, Phnom Penh, Cambodia. E-mail. info@teangtnaut.org Web. www.teangtnaut.org

# អង្គការសមាគមធាងត្នោត
Sahmakum Teang Tnaut Organization • a Cambodian Urban NGO

## តារាងសម្រង់តម្លៃ / Quotation Form

តារាងសំណើសុំសម្រង់តម្លៃ (Quotation ) ការផ្គត់ផ្គង់សម្ភារៈឈើ ជូនដល់សហគមន៍គោលដៅ របស់អង្គការសមាគមធាងត្នោត ក្នុងរាជធានីភ្នំពេញ ដូចមានរៀបរាប់ក្នុងតារាងខាងក្រោម៖

| ល.រ | ពិពណ៌នា | ចំនួន | ខ្នាត | តម្លៃរាយ | តម្លៃសរុប |
|---|---|---|---|---|---|
| No. | Description | Quantity | Unit | Unit Price | Total |
| 1 | សសរមូលគគីខ្សាច់ Wooden column 0.13 x 6m | 31 | ដើម | | |
| 2 | សសរមូលគគីខ្សាច់ Wooden column 0.13 x 5m | 76 | ដើម | | |
| 3 | ផ្ដាឈើក្រហម Plan 0.04 x 0.04 x 4m | 131 | ដើម | | |
| 4 | របាជញ្ជាំងឈើក្រហម Wall rail 0.04 x 0.04 x 5m | 270 | ដើម | | |
| 5 | ផ្ដោក្រហម Rafter 0.4 x 0.12 x 3m | 76 | ដើម | | |
| 6 | ធ្នឹម (ឈើក្រហម) Beam width 0.4 x 0.12 x 4m | 234 | ដើម | | |
| 7 | ធ្នឹម (ឈើក្រហម) Beam length 0.4 x 0.12 x 5m | 142 | ដើម | | |
| 8 | ក្ដា (ផ្ចៀកឬឈើក្រហម) Wooden wall 0.02 x 0.2 x 3m | 118 | សន្លឹក | | |
| 9 | ក្ដា (ផ្ចៀកឬឈើក្រហម) Wooden floor 0.02 x 0.2 x 4m | 168 | សន្លឹក | | |
| 10 | អ៊ីសូឡង់ Insulation 0.004 x 1.22 x 40m | 16 | ដុំ | | |
| 11 | ស័ង្កសីស្ដើងធម្មតា(ចិនឬវៀតណាម) Zinc wall 0.6 x 3m | 220 | សន្លឹក | | |
| 12 | ស័ង្កសីស្ដើងធម្មតា(ចិនឬវៀតណាម) Zinc Roof 0.6 x 2.4m | 86 | សន្លឹក | | |
| 13 | ស័ង្កសីស្ដើងធម្មតា(ចិនឬវៀតណាម) Zinc Roof 0.6 x 3m | 116 | សន្លឹក | | |
| 14 | ស័ង្កសីស្ដើងធម្មតា(ចិនឬវៀតណាម) Zinc Roof 0.6 x 3.6m | 22 | សន្លឹក | | |
| 15 | ដែកគោល Nail 0.08m | 15 | សុង | | |
| 16 | ដែកគោល Nail 0.10m | 15 | សុង | | |
| 17 | ដែកគោលមួក Head nail | 45 | គីឡូ | | |
| | | | | តម្លៃសរុប/Total | |
| | | | | អាករលើតម្លៃបន្ថែម/VAT 10% | |
| | | | | តម្លៃសរុបរួម/Grand-Total | |

លក្ខខណ្ឌផ្សេងៗ៖ (សូមមេត្តាបញ្ជាក់ព័ត៌មានបន្ថែមទៅលើតារាងតម្លៃដូចជា សុពលភាព របៀបនៃការទូទាត់ រយៈពេលនៃការទទួលបានទំនិញ ការធានា និងព័ត៌មានផ្សេងៗដែលពាក់ព័ន្ធ)

១. ..........................................................................................

..........................................................................................

២. ..........................................................................................

..........................................................................................

អាសយដ្ឋាន៖ ផ្ទះលេខ ២១ ផ្លូវលេខ៤៧២ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរសព្ទលេខ (៨៥៥)២៣ ៤៣១ ៥៥៥
ប្រអប់សំបុត្រលេខ ១៧៤ ភ្នំពេញ កម្ពុជា អ៊ីមែល info@teangtnaut.org គេហទំព័រ: www.teangtnaut.org
Address: #21, St 472, Tuol Toumpong I, Chamkar Mon, Phnom Penh. Tel: (855)23 431 555
P.O. Box 174, Phnom Penh, Cambodia. E-mail. info@teangtnaut.org Web. www.teangtnaut.org

៣. ……………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………

៥. ……………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………

ហត្ថលេខា ឈ្មោះអ្នកផ្តត់ផ្គង់ និងត្រា

……………………………………………